# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៦២៤៨ [illegible]

## សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្ដូរ តម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្ដាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី១០ ខែកក្កដា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិអង្គកែវ ក្នុងសង្កាត់ចោមចៅ ភូមិកន្ទោក ភូមិអង្គខាងលិច ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដំណាក់ធំ៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ (៣)តំបន់ភ្លើងលេខ ប.ត056 ស្ថិតនៅក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ (៤)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជើងឯក ចាប់ពីភូមិម៉ុល ក្នុងសង្កាត់ដង្កោ រហូតដល់ភូមិព្រែកប្រណាក់ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ (៥)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៤ ចាប់ពីភូមិត្រពាំងក្រពើ រហូតដល់ភូមិក្រាំងម្កាក់ ក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល និង (៦)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិស្រែជំរៅ ភូមិព្រៃល្វ ភូមិត្រពាំងរំចេក ភូមិទួលពង្រ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

២. ថ្ងៃសៅរ៍ទី១២ ខែកក្កដា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់ច្បារអំពៅ១ រហូតដល់សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវទំនប់អូស្ត្រាលី ចាប់ពីភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ រហូតដល់ភូមិត្នោតជ្រុំ ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវែងស្រេង ចាប់ពីភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៤)តំបន់ភ្លើងលេខ P019 ស្ថិតនៅភូមិខ្វារ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៣. ថ្ងៃអាទិត្យទី១៣ ខែកក្កដា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជើងឯក ចាប់ពីភូមិម៉ុល រហូតដល់ភូមិបាគូ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវែងស្រេង ចាប់ពីភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៣)តំបន់ភ្លើងលេខ P019 ស្ថិតនៅភូមិខ្វារ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា

កែវ រតនៈ